# ខជ្ជោបនកជាតក



*ខជ្ជោបនកបញ្ហា (បញ្ហាប្រាកដស្មើដោយអំពិលអំពែក) នេះ មានពាក្យថា កោ នុ សន្តម្ហិ បជ្ជោតេ នឹងមានជាក់ក្នុងមហាឧមង្គជាតក (មហោសថជាតក) ។*

***សេចក្ដីខាងក្រោមនេះជាអត្ថន័យដែលមានក្នុងព្រះបាលី ៖***

(ទេវតាពោលថា)

កោ នុ សន្តម្ហិ បជ្ជោតេ, អគ្គិបរិយេសនំ ចរំ;
អទ្ទក្ខិ រត្តិ ខជ្ជោតំ, ជាតវេទំ អមញ្ញថ។

*នរណាហ្ន៎ កាលបើពន្លឺមាន ត្រាច់ទៅស្វែងរកភ្លើង បានឃើញនូវអំពិលអំពែក ក្នុងវេលាយប់ ក៏សម្គាល់ថាភ្លើង ។*

សុស្ស គោមយចុណ្ណានិ, អភិមត្ថំ តិណានិ ច;
វិបរីតាយ សញ្ញាយ, ជាសក្ខិ បជ្ជលេតវេ។

បុរសនោះ ក៏ប្របាច់ឈ្មីនូវលំអិតនៃអាចម៍គោ និងស្មៅ ដោយសេចក្ដីសម្គាល់ខុស មិនអាចនឹងបង្កាត់ភ្លើង ឲ្យឆេះឡើងបានទេ ។

ឯវម្បិ អនុបាយេន, អត្ថំ ន លភតេ មិគោ;
វិសាណាតោ គវំ ទោហំ, យត្ថ ខីរំ ន វិន្ទតិ។

បុគ្គលកាលរូតទឹកដោះមេគោអំពីស្នែង រមែងមិនបាននូវទឹកដោះ យ៉ាងណា បុគ្គលអន្ធពាល ក៏មិនបាននូវប្រយោជន៍ ដោយហេតុមិនមែនឧបាយ យ៉ាងនោះដែរ ។

វិវិធេហិ ឧបាយេហិ, អត្ថំ បប្បោន្តិ មាណវា;
និគ្គហេន អមិត្តានំ, មិត្តានំ បគ្គហេន ច។

ជនទាំងឡាយ តែងបាននូវប្រយោជន៍ ដោយឧបាយទាំងឡាយផ្សេង ៗ គឺការផ្ចាញ់ផ្ចាល់សត្រូវទាំងឡាយផង គឺការទំនុកបម្រុង ចំពោះមិត្តទាំងឡាយផង ។

សេនាមោក្ខបលាភេន, វល្លភានំ នយេន ច;
ជគតឹ ជគតិបាលា, អាវសន្តិ វសុន្ធរំ។

ពួកអ្នករក្សាផែនដី រមែងគ្រប់គ្រងនូវផែនដី ដែលទ្រទ្រង់នូវទ្រព្យសម្បត្តិ ដោយការបំពេញបំបាន ចំពោះសេនាជាប្រធានផង ដោយការណែនាំ របស់ពួកមន្ត្រី ដែលជាអ្នកស្និទ្ធស្នាលផង ។

ចប់ ខជ្ជោបនកជាតក ៕

(សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បញ្ចកនិបាត វណ្ណារោហវគ្គ បិដកលេខ ៥៩ ទំព័រ ១៩ និង អដ្ឋកថា)

ថ្ងៃ ច័ន្ទ ១១ កើត ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ប.ស. ១៣៨០ ម.ស. ១៩៤០

ថ្ងៃទី ២៣ ខែ កក្កដា ព.ស. ២៥៦២ គ.ស.២០១៨

ដោយស.ដ.វ.ដ.